# ជម្លោះនិងការកាត់ក្តីក្នុងសិលាចារឹកអ្នកតាចារឹក K.១៨១

យោងតាមឯកសារលោក អេតៀន អៃម៉ូនីញេ៉រ ទួលអ្នកតាចារឹកជាបុរាណដ្ឋានមួយដែលនៅមិនឆ្ងាយប៉ុន្មានពីបារាយណ៍ទឹកមួយ និងស្ថិតនៅក្បែរភូមិរាជស្តេច ក្នុងខេត្តសៀមរាប(បច្ចុប្បន្នខេត្តព្រះវិហារ)។[១] លោកក៏បានបង្ហាញថាមានទីតាំងនៅខាងត្បូងភ្នំត្បែងប្រមាណ១០គីឡូម៉ែត្រ ខាងត្បូងឆៀងអាគ្នេយ៍កោះកេរ២០គីឡូម៉ែត្រ និងខាងលិចឆៀងនិរតីម្លូព្រៃ៥៣គីឡូម៉ែត្រ។ ចំណែកឯគេហទំព័រស្ថានីយ៍បុរាណវិទ្យានៅក្នុងប្រទេសកម្ពុជា (CISARK) បានបញ្ជាក់ថាទីតាំងនេះ បច្ចុប្បន្នស្ថិតនៅក្នុងភូមិក្តី ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ចម្ងាយ៣០០ម៉ែត្រអាគ្នេយ៍ភូមិអន្ទង់ភ្លូ និងឆ្ពៀសានភ្នំម្រេច ខាងត្បូងភ្នំត្បែង។[២] នៅទីតាំងនេះ គេធ្លាប់រកឃើញសិលាចារឹកមួយផ្ទាំង ចុះលេខ K.១៨១ ចារលើថ្មភក់ព័ណ៌ក្រហមមានសណ្ឋានជាសន្ទឹកសីមាមានប្រវែង ១,២ម. x ០,៣ម. x ០,២ម.។[៣] សិលាចារឹកនេះចារបីមុខជាភាសាខ្មែរសម័យអង្គរ ដោយមុខ “ក” មាន១៩បន្ទាត់ មុខ “ខ” មាន១៧បន្ទាត់ មុខ “គ” មាន៩បន្ទាត់។

អត្ថបទសិលាចារឹកនេះ ជាឧទាហរណ៍មួយនៅក្នុងសង្គមខ្មែរកាលពីបុរាណដែលបង្ហាញពីការរំលោភលើកម្មសិទ្ធិដោយមន្ត្រី ដែលប្រើមនុស្សឱ្យទៅដកបង្គោលសិលាចារឹកព្រំដីនិងប្រូតស្រូវរបស់គេ។ សិលាចារឹកនេះ គឺជាព្រះរាជសាសន៍របស់ព្រះបាទរាជេន្ទ្រវម៌្មទេវ (រាជេន្ទ្រវរ្ម័ន) ដោយបញ្ជាឱ្យតុលាការដោះស្រាយបញ្ហាវិវាទដែលអភិបាលខេត្តវីរបុរបានរំលោភយកដីរបស់វាបចូនិងគ្រួសារ ដែលបានថ្វាយដល់ប្រាសាទព្រះកុល។ សាច់រឿងចាប់ផ្តើមបន្ទាប់ដោយការរៀបរាប់ពីប្រវត្តិរបស់ដីនេះ បញ្ហាវិវាទ ការកាត់ក្តីដោយមានការពិន័យជាមាស វាយខ្នងដោយរំពាត់ និងបញ្ចប់ដោយការប្រគល់ដីដល់ម្ចាស់ដើមវិញ ព្រមទាំងមានការកំណត់ព្រំដីផងដែរ។ ដូច្នេះយើងឃើញថាកាលពីបុរាណមានប្រព័ន្ធតុលាការជាក់ច្បាស់មួយ ដើម្បីដោះស្រាយបញ្ហានានានៅក្នុងសង្គម ដែលមានព្រះរាជាជាតុលាការកំពូល ជួយដោះស្រាយនូវទំនាស់នានា ទោះបីជាមានមន្ត្រីមានអំណាចរំលោភបំពានច្បាប់ ក៏ត្រូវដោះស្រាយតាមផ្លូវតុលាការ ដើម្បីរកយុត្តិធម៌ដោយស្មើភាពដែរ។

---

[១] Aymonier 1900: 384

[២] https://cisark.mcfa.gov.kh/core/showsite.php?id=253

[៣] Coedès 1954: 140

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## អត្ថបទសិលាចារឹកជាអក្សរខ្មែរទំនើប

មុខក

១- ៨៨៤គកនុមាន[វ្រះ]
២- គាសនធូលិវ្រះបាទធូ( លិជេ)
៣- ងវ្រះកម្រតេងអញ្ញប្រេ[ស្ត]
៤- បិវ្យវហារម្រតាញ្ញកុរុង( រី)
៥- រកក្តិគដ្ធិតខ្ញោញ្ញវិថយរី
៦- របូរ មនិម្រតាញ្ញកុរុងប្រេអ្ន( កិ)
៧- ទៅតោកិគោលិប្រគស្តតគិស្រេប្រេ
៨- ច្រូតិស្រុ មនិភូមិនេះភូមិវា
៩- បង៌ាចិឱបាធ្យាយថ្មោងបិ តិម្រ
១០- តាញ្ញខ្ញោញ្ញគ្រីវិវេទ្រូវម្ម៌នុម្រ
១១- តាញ្ញគ្រីន្ទប្ញបេទ្រូរិមថនឱយិ
១២- ធនតវាបិង៌ាចិបិស្វំទេបិប( ង្គំ)
១៣- ថ្ប្លោងនិវេទនបិមានវ្រ[[ះ]]គា
១៤- សនប្រេទៅសំគោលិប្រគ
១៥- ស្តតគិបិឱយិតវាបិចូនុ
១៦- កុលេវាបិចូតទៅវ្រះក
១៧- រុណាប្រសាទតកំម្រ
១៨- តេងវ្រះកុល គិនេះភូមិ
១៩- នេះគិបិម្រតាញ្ញកុរុង

មុខខ

១- តោកិគោលិប្រគស្តច្រូ
២- ចិស្រុតគិមន្តិស្តបិវ្យវ
៣- ហារមានិម្រតាញ្ញកុរុង
៤- បំវ្យត្តនេះអំវេតពោះហ
៥- នេះហបិកថាមនិហេតុ
៦- វាបិអម្ញុបតកថាមនិភូ
៧- មិទៃបិប្រេម្រតាញ្ញកុរុងតោ
៨- កិគោលិប្រគស្តតិសភា
៩- និណ្ណ៌យម្រតាញ្ញកុរុងមា
១០- សិលិង១០ វាបិគ្រីតផ្លូនិ
១១- ម្រតាញ្ញកុរុងតតិប្រេច្រូត្ត
១២- ស្រុតគិតិត្រានិណ្ណ៌យបុប្ញម្ព
១៣- តាទន១០០ ២ វាបិអម្ញុបត្តទៃ
១៤- តិកថាមនភូមិទៃបិអ
១៥- ញូតិនិណ្ណ៌យបុប្ញម្ពតាទន
១៦- ១០០ ២ វាបិបិតិគិតនាំអ្នកិ
១៧- ទៅច្រូតិស្រុបិតិស្តបិវ្យវ

មុខគ

១- ( ហារ)----ទៅប្រា
២- --ជ្យង១ ចាវេបិគុទ្វរ-
៣- -ស្រេតិប្រេ( សិ)ទ្វិវិងតវា
៤- បិចូនុកុលេវាបិ វាបិចូ
៥- ( ភូមិ)កំម្រតេងអញ្ញប្ញ្វំ
៦- -ប្រសប្តោលិបគ្និម
៧- ( ប្រ)សប្តោលិឧត្តរប្រស
៨- ប្តោលិទក្ខិណប្រសប្តោ
៩- ( លិ)๏

## សេចក្ដីប្រែសម្រួល

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ឆ្នាំ៨៨៤មហាសករាជ (៩៦២គ.ស.) មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញប្រើ (សភា/តុលាការ) ស្តាប់រឿងក្តីម្រតាញកុរុងវីរកក្តិគដ្ឋិដែលជាអភិបាលខេត្តវីរបុរ។ ម្រតាញកុរុង (នេះ) ប្រើគេឱ្យទៅដកថ្មគោលសិលាចារឹក ប្រើប្រូតស្រូវ។ ដីនេះគឺដីរបស់វាបង្អាច់ជាឧបាធ្យាយថ្មោងបី។ ម្រតាញខ្លោញស្រីវីរេន្ទ្រវម្ម័ និងម្រតាញស្រីទ្រីបេន្ទ្រារិមថន(បាន)ឱ្យទ្រព្យដល់វាបង៉ាចដែលបានសុំ។ (ក្រោយមក) ទើបបង្គំថ្ប្លងទូលថ្វាយដើម្បីសុំព្រះរាជសាសន៍ឲ្យទៅសង់គោលសិលាចារឹក និងឱ្យ(ដីនោះ)ដល់វាបចូនិងក្រុមគ្រួសារវាបចូនិងថ្វាយដល់(ប្រាសាទ)ព្រះគម្តែងព្រះកុល។ នេះគឺដីភូមិដែលម្រតាញកុរុងដកគោលសិលាចារឹកនិងប្រូតស្រូវ។ នៅពេលបានស្តាប់រឿងក្តីម្រតាញកុរុងដែលបានធ្វើពិតដូចអំពើដែលរៀបរាប់មកនេះ (ទើបដឹង) រឿងហេតុ (ដំបូង) ថាវាបអម្រឹតប្រាប់ថា (ដីនេះជា)ដីផ្សេងទេ ដើម្បីប្រើម្រតាញកុរុងដកគោលចារឹក(នោះចោល)។ សភាជម្រះក្តី (ដោយពិន័យ)ម្រតាញកុរុង(ជា)មាស១០តម្លឹង។ វាបស្រីជាប្អូនម្រតាញកុរុងដែលប្រើប្រូតស្រូវ (សភា)ជម្រះក្តីដោយវាយខ្នង១០២រំពាត់។ (ចំណែកឯ)វាបអម្រឹតដែលបានរៀបរាប់ថានោះជាដីផ្សេងដើម្បី(ឲ្យគេ)ទិញ(យក) (សភា)ជម្រះក្តីដោយវាយខ្នង១០២រំពាត់។ វាបបតិអ្នកនាំគេទៅប្រូតស្រូវ (តុលាការ)ស្តាប់រឿងក្តី---ទៅប្រា---១ជញ្ជីង។ អ្នកស៊ើបរឿងក្តីទាំងបី (រកឃើញថាវាបបតិ) បរិសុទ្ធ (និង) ឱ្យរួចទោស (*ដោយសាររលុបទើបពិបាកយល់ន័យ)។ ដីស្រែ (នេះ) ឱ្យសិទ្ធិកាន់កាប់វិញដល់វាបចូនិងក្រុមគ្រួសារវាបចូ។ ដីព្រះគម្តែងអញខាងកើតទៅប្រសប់គោល ខាងលិចទៅប្រសប់គោល ខាងជើងទៅប្រសប់គោល ខាងត្បូងទៅប្រសប់គោល ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



ទីតាំងអ្នកតាចារឹក (រូបថត៖ CISARK)



ទីតាំងអ្នកតាចារឹក (រូបថត៖ CISARK)



សិលាចារឹកអ្នកតាចារឹក (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



n. 756-B / K. 181-B



n. 756-A / K. 181-A



n. 756-C / K. 181-C

សំណៅផ្តិតសិលាចារឹកអ្នកតាចារឹក (រូបថត៖ EFEO តាមរយៈ CISARK)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

## ឯកសារយោង

Aymonier, E.
(1900). *Le Cambodge. Tome1. Paris.*
Coedes, G.
(1954). *Inscriptions du Cambodge*. Vol. 6. Paris: École Française d'Extrême-Orient.
CISARK
https://cisark.mcfa.gov.kh/core/showsite.php?id=253

អត្ថបទដោយ៖ ហ៊ុន ឈុនតេង